# បាឋកថាទិវាគ្រូបង្រៀន

# បរិវត្តកម្មឌីជីថលនៃការអប់រំ

# ការអនុវត្តវិធីសាស្ត្របង្រៀនថ្មី

# ផ្នែកទី១

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

៥ តុលា ២០២១

# សេចក្ដីផ្ដើម

- ដើម្បីឱ្យមានសេដ្ឋកិច្ចបែបឌីជីថល លុះត្រាតែមានការអប់រំបែបឌីជីថល
- មូលដ្ឋានគ្រឹះសម្រាប់ការអប់រំឌីជីថលត្រូវឆ្លើយតបជាមួយយុគសម័យបច្ចេកវិទ្យា
- កម្ពុជាត្រូវការធនធានមនុស្សដែលមានគុណភាពខ្ពស់ ដើម្បីប្រណាំងប្រជែងនៅក្នុងតំបន់ និងបង្កើតវិស័យសេដ្ឋកិច្ច ថ្មីៗ ដូចជាអេឡិចត្រូនិច កសិ-ឧស្សាហកម្ម ឡូជិសស្ទិកនៅក្នុងយុគឌីជីថល
- តើយុវជនត្រូវការអ្វីខ្លះក្នុងយុគសម័យបដិវត្តន៍ឧស្សាហកម្មទី៤? តើអ្វីទៅជាបំណិនសតវត្សទី២១?
- តើគេអាចអប់រំយុវជនឱ្យមានបំណិនសតវត្សទី២១ បានដែរឬទេ? ដើម្បីឆ្លើយនឹងសំណួរនេះយើងត្រូវសិក្សាទ្រឹស្ដីនៃការសិក្សាជាមុនសិន
- ការសិក្សា គឺជាការកែប្រែអាកប្បកិរិយា ដែលជាផលទទួលបានពីបទពិសោធ ដែលមនុស្សទទួលបានពីការជួបប្រសព្វជាមួយបរិស្ថានជុំវិញ ឬពីការហ្វឹកហាត់ រួមទាំងការប្រែប្រួលនៃបរិមាណនៃចំណេះដឹងរបស់អ្នកសិក្សា។

# សេចក្តីផ្តើម

- គ្រូបង្រៀនមានភារកិច្ចក្នុងការជួយសិស្សគ្រប់រូប ឱ្យចេះរៀន មានវិជ្ជាសម្បទា មានបំណិនសម្បទា និងចរិយាសម្បទា ទៅតាមកម្មវិធីសិក្សាកំណត់។ គ្រូត្រូវរៀបចំបរិស្ថានថ្នាក់រៀន ដើម្បីបង្កើតបរិយាកាសសម្រាប់ការរៀន និងជួយសិស្សឱ្យកែប្រែ និងផ្លាស់អាកប្បកិរិយាទៅតាមគោលដៅនៃកម្មវិធីសិក្សា
- ដើម្បីបង្រៀនល្អ គ្រូត្រូវចេះរៀបចំផែនការគរុកោសល្យ ដូចជាកិច្ចតែងការបង្រៀន
- គ្រូត្រូវប្រើវិធីបង្រៀនផ្សេងៗដើម្បីជួយសម្រួលការសិក្សារបស់សិស្ស និងសម្រេចឱ្យបានតាមស្តង់ដាកម្មវិធីសិក្សារបស់ក្រសួង
- គ្រូត្រូវចេះវិធីសាស្ត្រ ក្នុងការពន្យល់ពីបញ្ញត្តិតាមដំណាក់កាល ដោយប្រើវិធីសាស្ត្រអនុមានរួម និងអនុមានញែក និងប្រើប្រាស់បញ្ញត្តិ និងទ្រឹស្តីបទ ដែលទាក់ទងគ្នា ដើម្បីជួយសិស្សរៀនឱ្យចេះ ក្នុងការរៀនបញ្ញត្តិថ្មី។

# ទី១- សេដ្ឋកិច្ចឌីជីថល



# បដិវត្តន៍ឧស្សាហកម្មលើកទី៤





# ១.បរិវត្តកម្មឌីជីថល និងសេដ្ឋកិច្ចឌីជីថល

- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី បានដាក់ចេញនូវចក្ខុវិស័យប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ ២០៣០។
- យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤ បានចង្អុលបង្ហាញអំពីភាពចាំបាច់ក្នុងការត្រៀមខ្លួនសម្រាប់ សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤ សំដៅទាញយកអត្ថប្រយោជន៍ជាអតិបរមាពីការរីកចម្រើនយ៉ាងឆាប់រហ័សផ្នែកបច្ចេកវិទ្យា និងឌីជីថលូបនីយកម្ម ទាំងក្នុងប្រទេស តំបន់ និងសកល។
- នៅថ្ងៃទី ១០ ឧសភា ២០២១ រាជរដ្ឋាភិបាលកម្ពុជាអនុមតិ «ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចឌីជីថលកម្ពុជា»។

# ១.បរិវត្តកម្មឌីជីថល និងសេដ្ឋកិច្ចឌីជីថល

- ការធ្វើបរិវត្តកម្មឌីជីថល (Digital Transformation) ទាំងផ្នែកសេដ្ឋកិច្ច និងផ្នែកសង្គមសម្រាប់កម្ពុជា, ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចឌីជីថលកម្ពុជា បានពង្រីកវិសាលភាពគ្របដណ្តប់ទាំងលើផ្នែកសង្គមឌីជីថលផងដែរ ដោយប្រែក្លាយជា ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ។
- ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា គឺជាឯកសារយុទ្ធសាស្ត្រដែលបានឆ្លុះបញ្ចាំងពីការគិតគូរវែងឆ្ងាយរបស់រាជរដ្ឋាភិបាល ក្នុងគោលដៅកសាងសង្គម និងសេដ្ឋកិច្ចឌីជីថល ឱ្យក្លាយជាចន្ទល់កំណើនសេដ្ឋកិច្ចថ្មី ព្រមទាំងចូលរួមចំណែកលើកកម្ពស់ភាពប្រកួតប្រជែង និងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជននៃសង្គមឌីជីថលកម្ពុជា។

# ១.បរិវត្តកម្មឌីជីថល និងសេដ្ឋកិច្ចឌីជីថល

- ក្របខ័ណ្ឌគោលនយោបាយនេះ នឹងចាប់យកនូវកាលានុវត្តភាព និងសក្តានុពលទាំងឡាយពីវិស័យបច្ចេកវិទ្យាឌីជីថល សំដៅធ្វើយ៉ាងណាប្រើប្រាស់វិស័យបច្ចេកវិទ្យាឌីជីថល សម្រាប់ធ្វើការពង្រួញផ្លូវ និងពន្លឿនការអភិវឌ្ឍប្រទេស, និងការដោះស្រាយបញ្ហាប្រឈមនានា ដែលកំពុងមានស្រាប់ ក៏ដូចជាបញ្ហាប្រឈម និងផលប៉ះពាល់អវិជ្ជមាននានា ដែលអាចកើតមានឡើងជាយថាហេតុ ដោយសារឥទ្ធិពលនៃការប្រើប្រាស់បច្ចេកវិទ្យាឌីថីថល។
- ស្ថិតក្នុងបរិការណ៍នៃវិបត្តិជំងឺកូវីដ-១៩ ឯកសារគោលនយោបាយនេះ ក៏នឹងក្លាយជាឧបករណ៍មួយដ៏យ៉ាងសំខាន់ នៃផែនការស្តារសេដ្ឋកិច្ចក្រោយវិបត្តិកូវីដ-១៩ របស់កម្ពុជាពោលគឺផ្តល់ការគាំទ្រ ទាំងដោយផ្ទាល់ និងប្រយោល ក្នុងការជំរុញកំណើនសេដ្ឋកិច្ច តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថលសម្បូរបែប, ឡជីស្ទីក, ការទាក់ទាញវិនិយោគ, ការបង្កើតផលិតភាព និងការលើកកម្ពស់ភាពប្រកួតប្រជែងជាដើម។

# ១.បរិវត្តកម្មឌីជីថល និងសេដ្ឋកិច្ចឌីជីថល

- ក្នុងន័យចង្អៀត សេដ្ឋកិច្ចឌីជីថលគឺជាទីផ្សារ ដែលពឹងផ្អែកលើបច្ចេកវិទ្យាឌីជីថលក្នុងការសម្រួលដល់ការដោះដូរទំនិញ និងការផ្តល់សេវាតាមរយៈពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬម្យ៉ាងទៀតគឺជាការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ផ្អែកលើអ៊ីនធឺណេតនៅក្នុងដំណើរការផលិតកម្ម និងការដោះដូរទំនិញ ក៏ដូចជាសេវា។
- ក្នុងន័យទូលំទូលាយ សេដ្ឋកិច្ចឌីជីថលសំដៅទៅដល់ប្រព័ន្ធទំនាក់ទំនងសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលពឹងផ្អែកលើការប្រើប្រាស់ប្រព័ន្ធ ICT និងឌីជីថល។
- សេដ្ឋកិច្ចឌីជីថល គឺជាដំណើរការសេដ្ឋកិច្ចដែលចរាចរលើប្រព័ន្ធអ៊ិនធឺណែតដែលមានជំនួយពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដែលជំរុញឱ្យមានការតភ្ជាប់ កាន់តែទូលំទូលាយរវាង និងក្នុងចំណោមមនុស្ស ពាណិជ្ជកម្ម ឧបករណ៍ និងទិន្នន័យ។ ព័ត៌មាន និងចំណេះដឹងត្រូវប្រើប្រាស់ដើម្បីពង្រឹង និងពង្រីកសកម្មភាពផលិតកម្ម។

# ១.បរិវត្តកម្មឌីជីថល និងសេដ្ឋកិច្ចឌីជីថល

- ការប្រែក្លាយឆ្ពោះទៅរកសេដ្ឋកិច្ចផ្អែកឌីជីថលស្របពេលការរីកចម្រើននៃបដិវត្តឧស្សាហកម្មទី៤ (ឧស្សាហកម្ម ៤.0) អាចនឹងក្លាយជាក្បាលម៉ាស៊ីនថ្មីមួយសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ដើម្បីសម្រេចបានផែនការប្រែក្លាយកម្ពុជាជាប្រទេសចំណូលខ្ពស់នាពេលខាងមុខ។

# ទី២
# បរិវត្តកម្មឌីជីថលនៃការអប់រំ



# ២.បរិវត្តកម្មឌីជីថលនៃការអប់រំ

- ដើម្បីឱ្យមានសេដ្ឋកិច្ចបែបឌីជីថល លុះត្រាតែមានការអប់រំបែបឌីជីថល។
- ការអប់រំឌីជីថលក្នុងបរិបទឧស្សាហកម្ម៤.0 មានសារសំខាន់ខ្លាំងណាស់សម្រាប់ប្រទេសកម្ពុជា ក្នុងការបោះជំហានឱ្យក្លាយជាប្រទេសដែលមានសេដ្ឋកិច្ចបែបឌីជីថល និងរដ្ឋាភិបាលឌីជីថល ព្រោះផ្នែកទាំងអស់នេះត្រូវការអ្នកជំនាញជាច្រើនដើម្បីបំពេញការងារ និងគ្រប់គ្រងប្រព័ន្ធវៃឆ្លាតទាំងអស់នោះ។
- ក្នុងន័យនេះ មូលដ្ឋានគ្រឹះសម្រាប់ការអប់រំឌីជីថល ត្រូវឆ្លើយតបជាមួយយុគសម័យបច្ចេកវិទ្យា ដោយការធ្វើកំណែទម្រង់សាលារៀន និងកំណែទម្រង់ការបណ្តុះបណ្តាលគ្រូ ដោយធ្វើយ៉ាងណាឱ្យភាគីពាក់ព័ន្ធទាំងអស់មានសមត្ថភាពខ្ពស់។

# ២.១. បរិស្ថានសម្រាប់ការអប់រំឌីជីថល

- នៅក្នុងយុគសម័យឌីជីថល បច្ចេកវិទ្យាមានតួនាទីយ៉ាងសំខាន់ក្នុងការសិក្សា។ គ្រូបង្រៀន និងសិស្សអាចប្រើកុំព្យូទ័រ ទូរស័ព្ទដៃ ឧបករណ៍អេឡិកត្រូនិកផ្សេងទៀត ប្រព័ន្ធបណ្តាញសង្គម ដើម្បីបង្កើតជាប្រព័ន្ធសិក្សាអេឡិកត្រូនិក និងវេទិកាឌីជីថល ដើម្បីសម្រួលដល់ការសិក្សា។ ការរៀបចំបរិស្ថានសម្រាប់ការសិក្សាក្នុងយុគសម័យឌីជីថល គឺជាកត្តាគន្លឹះនៃការអប់រំឌីជីថល។ បរិស្ថានសម្រាប់ការសិក្សានៅក្នុងយុគសម័យឌីជីថលរួមមាន៖
- **ប្រព័ន្ធគ្រប់គ្រងការសិក្សា** (Learning Management System-LMS)៖ ប្រព័ន្ធគ្រប់គ្រងការសិក្សា ផ្តល់ការអប់រំអេឡិចត្រូនិក ដោយប្រើប្រាស់កម្មវិធី Apps ដូចជា Google suit, Moodle, BlackBoard ដែលជាប្រព័ន្ធធំ និងស្មុគស្មាញ ដែលគ្រប់គ្រងការរៀន និងបង្រៀនពីចម្ងាយតាមបែបអេឡិចត្រូនិក ដោយគ្រូបង្រៀន live ពីចម្ងាយដោយប្រើប្រាស់បទបង្ហាញ PowerPoint, ហើយសិស្សចូលរៀននៅក្នុងបន្ទប់រៀនសិប្បនិម្មិត (Virtual) និងមានបន្ទប់ពិភាក្សា ដំណភ្ជាប់វេបសាយ (Weblinks) បណ្ណាល័យ ប្រតិទិន និងធនធានសិក្សាផ្សេងទៀត។

# ២.១. បរិស្ថានសម្រាប់ការអប់រំឌីជីថល

- **ប្រព័ន្ធគ្រប់គ្រងការសិក្សា** ខ្លះមានលក្ខណៈជាវេបសាយ ដែលសិស្សអាចចុះឈ្មោះចូលរៀនតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់ ដោយគ្មានគ្រូបង្រៀន ហើយមានការធ្វើតេស្តជាស្វ័យប្រវត្តិតាមម៉ូឌុល មុននឹងអាចឡើងថ្នាក់រៀនក្នុងកម្រិតខ្ពស់ជាងមុន។
- ក្រុមហ៊ុនឯកជនមួយចំនួនបានបង្កើតប្រព័ន្ធគ្រប់គ្រងការសិក្សា សម្រាប់សាលារៀនមួយៗ ដោយមានប្រព័ន្ធគ្រប់គ្រងវត្តមានសិស្ស ប្រព័ន្ធគ្រប់គ្រងការរៀននិងបង្រៀន ប្រព័ន្ធគ្រប់គ្រងធនធានសិក្សា និងប្រព័ន្ធទំនាក់ទំនងជាមួយមាតាបិតាផងដែរ។
- គេអាចបង្កើតកម្មវិធីកុំព្យូទ័របែប Apps ដែលផ្ទុកនូវខ្លឹមសារឌីជីថល ជាវីដេអូមេរៀនគ្រប់មុខវិជ្ជា និងគ្រប់កម្រិតថ្នាក់រៀន ដើម្បីជួយសិស្សក្នុងការទាញយក និងផ្ទុកក្នុងកុំព្យូទ័រផ្ទាល់ខ្លួន ឬទូរស័ព្ទដៃដើម្បីធ្វើការសិក្សាជាលក្ខណៈឯកជន។

# ២.១. បរិស្ថានសម្រាប់ការអប់រំឌីជីថល

- **ប្រព័ន្ធគ្រប់គ្រងការសិក្សាផ្ទាល់ខ្លួន** (Personal Learning System-PLS)៖ គឺជាឧបករណ៍គាំទ្រដល់ការសិក្សាផ្ទាល់ខ្លួន ដោយប្រើប្រាស់ឧបករណ៍អេឡិចត្រូនិក។ សិស្សអាចទាញយកខ្លឹមសារឌីជីថល ជាអត្ថបទ បទបង្ហាញ PowerPoint ឬ វីឌេអូ ដើម្បីរក្សាទុកក្នុងឧបករណ៍អេឡិចត្រូនិកផ្ទាល់ខ្លួនទុកសម្រាប់សិក្សានៅកន្លែងណា និងពេលណា ដែលខ្លួនចង់រៀន។ សិស្ស និងគ្រូអាចចងក្រុមជាបណ្តាញអ្នកសិក្សា ដោយ ប្រើប្រាស់កម្មវិធី Telegram, Messenger ឬ WhatApps ដើម្បីផ្លាស់ប្តូរ ព័ត៌មាន ចែករំលែកធនធានសិក្សា និងពិគ្រោះយោបល់ផងដែរ។
- **ការសិក្សាក្នុងថ្នាក់រៀនបញ្ច្រាស** (Flipped Classroom)៖ នៅក្នុងការបង្រៀនសិស្សតាមបែបប្រពៃណី គ្រូបង្រៀនមេរៀនដោយផ្ទាល់ និងផ្តល់បាឋកថានៅក្នុងថ្នាក់រៀន ចំណែកសិស្សត្រូវកត់មេរៀន និងស្តាប់គ្រូពន្យល់ក្នុងថ្នាក់រៀន។ នៅក្រៅថ្នាក់រៀន សិស្សត្រូវធ្វើកិច្ចការនៅផ្ទះ សរសេរគម្រោង និងធ្វើការអនុវត្តលើមេរៀន។

# ២.២. អក្ខរកម្មឌីជីថល

- យុគសម័យឌីជីថលបានផ្លាស់ប្តូរអត្ថន័យអក្ខរកម្ម ពីអក្ខរកម្មតាមបែបប្រពៃណី ទៅរក អក្ខរកម្មឌីជីថល (Digital literacy)។ **អក្ខរកម្មឌីជីថល** គឺជាបំណិនដែលចាំបាច់សម្រាប់ការសិក្សា ការរស់នៅ និងការបំពេញការងារនៅក្នុងសង្គមនៃសតវត្សទី២១ ដែលប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដូចជាវេទិកាអ៊ិនធ័រណែត បណ្តាញសង្គម និងឧបករណ៍អេឡិចត្រូនិកចល័ត។ អក្ខរកម្មឌីជីថលមានសមាសភាគ ៣ ផ្នែកសំខាន់ៗ គឺ៖ (១) 3Rs (២) 8Cs និង (៣) 2Ls។
- **សមាសភាគទី១- 3 Rs** ជានិយមន័យអក្ខរកម្មតាមបែបប្រពៃណីយ ដែលមាន៖ (១) អំណាន (Reading) (២) សំណេរ (W-Riting) និង (៣) លេខនព្វន្ត (A-Rithmetics)។
- **សមាសភាគទី២- 8Cs** អក្ខរកម្មក្នុងសតវត្សទី២១៖ (១) បំណិនត្រិះរិះ និងដោះស្រាយបញ្ហា (Critical thinking and problem solving) (២) បំណិនឆ្នៃប្រឌិត និងនវានុវត្តន៍(Creativity and innovation) (៣) អក្ខរកម្មកុំព្យូទ័រ និង បច្ចេកវិទ្យាឌីជីថល (Computing & digital tools) (៤) បំណិនសហការ និងធ្វើការជាក្រុម (Collaboration, teamwork) (៥) បំណិនគមនាគមន៍ព័ត៌មាន និងអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ (Communications, information & media literacy)

# ២.២. អក្ខរកម្មឌីជីថល

- (៦) បំណិនអាជីព និងរៀន (Career & learning skills) (៧) បំណិនខាងផ្នែកផ្លាស់ប្តូរ (Change) និង (៨) ការយល់ពីវប្បធម៌ផ្សេងៗគ្នា (Cross-cultural understanding)។
- **សមាសភាគទី៣- 2 Ls៖** (១) បំណិនក្នុងការរៀន (Learning Skills)៖ រៀន, បំភ្លេចចំណេះដឹងចាស់, និងរៀនឡើងវិញ និង (២) ភាពជាអ្នកដឹកនាំ (Leadership)។
- ការសរសេរកម្មវិធីកុំព្យូទ័រ (Computer coding)៖ ការសរសេរកម្មវិធីកុំព្យូទ័របានក្លាយជាមុខវិជ្ជាមួយដ៏សំខាន់សម្រាប់សិស្ស ដែលមានចំណាប់ចំណូលចិត្តខាងផ្នែកស្ថាបនាមនុស្សយន្ត (robotics) និងជាស្ពានចម្លងសម្រាប់ហ្វឹកហាត់សិស្ស ឱ្យចេះសរសេរកម្មវិធីកុំព្យូទ័រ និងស្ថាបនាកម្មវិធី Apps, វេបសាយ ល្បែងអេឡិចត្រូនិក ឧបករណ៍អេឡិចត្រូនិក និងម៉ាស៊ីនស្វ័យប្រវត្តិផ្សេងៗ។



# ទី៣

# ការអនុវត្តការអប់រំឌីជីថលនៅកម្ពុជា

# ៣.ការអនុវត្តការអប់រំឌីជីថលនៅកម្ពុជា

- ការអប់រំបែបឌីជីថល គឺជាការប្រើប្រាស់ឧបករណ៍ និងបច្ចេកវិទ្យាឌីជីថល ក្នុងការរៀន និងការបង្រៀន ក៏ដូចជាការគ្រប់គ្រងដែរ។
- ការរៀបចំប្រព័ន្ធអប់រំអេឡិចត្រូនិក និងការផ្តល់សេវារៀនពីចម្ងាយ ដោយបានដាក់ចេញ វិធានការជា ៣ ដំណាក់កាល រួមមាន ៖
- **ដំណាក់កាលបន្ទាន់៖** ការបង្កើតគណៈកម្មការពិសេសមួយ សម្រាប់ផលិតវីដេអូបង្រៀនសម្រាប់មុខវិជ្ជាគោល និងសម្រាប់ថ្នាក់ប្រឡង ព្រមទាំងបង្ហោះនិងផ្សព្វផ្សាយ លើវេទិកាឌីជីថលដែលមានស្រាប់
- **ដំណាក់កាលមធ្យម៖** ការកែលម្អវេទិកាឌីជីថលដែលមានស្រាប់របស់ក្រសួងអប់រំ យុវជន និងកីឡា ឱ្យបានកាន់តែប្រសើរ និងការផលិតវីដេអូបង្រៀនដែលចាំបាច់បន្ថែមទៀត
- **ដំណាក់កាលវែង៖** ការរៀបចំកែលម្អ និងអភិវឌ្ឍវេទិកាឌីជីថលសម្រាប់ផ្តល់សេវាអប់រំ តាមប្រព័ន្ធអេឡិចត្រូនិក ដែលមានលក្ខណៈសមរម្យ និងគ្រប់ជ្រុងជ្រោយ។

# ៣.ការអនុវត្តការអប់រំឌីជីថលនៅកម្ពុជា

- ក្នុងអំឡុងពេលនៃវិស្សមកាលមុនកាលកំណត់ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំវិធានការមួយចំនួនជាបន្តបន្ទាប់ ដូចជាការបង្កើតកម្មវិធីសិក្សា "ការរៀនតាមប្រព័ន្ធអេឡិចត្រូនិក"
- ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតគណៈកម្មការតាមអនុវិស័យ និងបានជ្រើសរើសលោកគ្រូអ្នកគ្រូ ដែលមានបទពិសោធ ក្នុងការបង្រៀនមកថតវីដេអូបង្រៀន និងបានជ្រើសរើសបន្ទប់សម្រាប់ថតជាបណ្ដោះអាសន្នមួយចំនួនដូចជា៖ នៅវិទ្យាល័យព្រះស៊ីសុវត្ថិ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នាយកដ្ឋានបឋមសិក្សា និងនាយកដ្ឋានអប់រំកុមារតូច។
- ក្រសួងបានចេញសេចក្ដីណែនាំស្ដីពី ការលើកកម្ពស់ការបង្រៀននិងរៀនពីចម្ងាយ ឬតាមប្រព័ន្ធអេឡិចត្រូនិកដល់គ្រឹះស្ថានសិក្សាចំណេះទូទៅ មាតាបិតា អាណាព្យាបាល និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីចូលរួមជំរុញការអនុវត្ត និងធានាបាននូវគុណភាព និងប្រសិទ្ធភាពក្នុងការបង្រៀននិងរៀន និងការវាយតម្លៃ។

# ៣.ការអនុវត្តការអប់រំឌីជីថលនៅកម្ពុជា

- សកម្មភាពសំខាន់ៗនៅក្នុងដំណាក់កាលបន្ទាន់ រួមមាន ៖
- I. **ដំណាក់កាលទី ១ ៖** ការផ្តោតលើសិស្សថ្នាក់ទី ៩ និងទី ១២
- ក្រសួងបានសម្រេចផលិតខ្សែវីដេអូលើមុខវិជ្ជាគោលចំនួន ៦ រួមមាន ភាសាខ្មែរ គណិតវិទ្យា ប្រវត្តិវិទ្យា គីមីវិទ្យា រូបវិទ្យា និងជីវវិទ្យាសម្រាប់ថ្នាក់ទី៩ និងថ្នាក់ទី១២ ដោយមានសាស្ត្រាចារ្យអញ្ជើញមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាល័យបាក់ទូក វិទ្យាល័យបឹងត្របែក និងវិទ្យាល័យព្រះស៊ីសុវត្ថិ
- ក្រសួងបានបង្កើតវេទិកាឌីជីថលចំនួន ៣ ដូចខាងក្រោម ដើម្បីរៀបចំប្រព័ន្ធអប់រំអេឡិចត្រូនិក៖
- **១. បណ្តាញYouTube ផ្លូវការរបស់ក្រសួង៖** www.youtube.com/moeys ដែលមានវីដេអូបង្រៀនទាំងអស់ សម្រាប់សិស្សានុសិស្សអាចសិក្សាបានទៅតាមពេលវេលាជាក់ស្តែងរបស់ខ្លួន

# ៣.ការអនុវត្តការអប់រំឌីជីថលនៅកម្ពុជា

- ២. **ទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួង៖** www.facebook.com/moeys.gov.kh ដែលធ្វើការផ្សព្វផ្សាយជារៀងរាល់ថ្ងៃ នៅពេលព្រឹកសម្រាប់ថ្នាក់ទី៩ និងពេលរសៀលសម្រាប់ថ្នាក់ទី១២
- ៣. **មជ្ឈមណ្ឌលសិក្សាអេឡិចត្រូនិករបស់ក្រសួង៖** www.elearning.moeys.gov.kh ដោយសិស្សានុសិស្សអាចចូលទៅសិក្សាបានតាមរយៈការជ្រើសរើសវគ្គសិក្សា ឬមេរៀនដែលត្រូវ សិក្សាដោយឥតគិតថ្លៃ និងមិនចាំបាច់ចុះឈ្មោះ
- ៤. ក្នុងរយៈពេល ៣ សប្តាហ៍ អ្នកទស្សនានៅលើវេទិកាឌីជីថលទាំង ៣ រួមមាន ទំព័រ Facebook ៥២០,000 នាក់ បណ្ដាញ Youtube ២៦៣,000 នាទី និង វេបសាយ ១000 ដង
- II. **ដំណាក់កាលទី ២ ៖** ការថតមេរៀនសម្រាប់សិស្សគ្រប់កម្រិត
- ១. **មត្តេយ្យសិក្សា ៖** មុខវិជ្ជាចំនួន៥ ត្រូវបានផលិតជាខ្សែវីដេអូសម្រាប់កុមារតូចនៅថ្នាក់មត្តេយ្យសិក្សារួមមាន៖ ១.ចិត្តចលភាព ២.វិទ្យាសាស្រ្ត ៣.សិក្សាសង្គម ៤.បុរេគណិត និង៥. ភាសាខ្មែរ។

# ៣.ការអនុវត្តការអប់រំឌីជីថលនៅកម្ពុជា

- **២. បឋមសិក្សា ៖** កម្មវិធី "កុមាររៀនកុមារចេះ" ដែលរួមមានកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាកម្រិតថ្នាក់ដំបូងនៅបឋមសិក្សា ដូចជា សៀវភៅណែនាំសម្រាប់គ្រូ និងឯកសារបង្រៀន និងរៀនសម្រាប់ប្រើប្រាស់ក្នុងមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាសម្រាប់សិស្សថ្នាក់ទី១ និងទី២ ដែលនឹងបំពេញបន្ថែមទៅលើសៀវភៅសិក្សាគោលភាសាខ្មែរ ដែលមានស្រាប់។ សម្រាប់ថ្នាក់ទី ៤ ដល់ទី៦ ក្រសួងបាន ផលិតវីដេអូបង្រៀនមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា។
- **៣. មធ្យមសិក្សា ៖** ខ្សែវីដេអូបង្រៀន សម្រាប់ថ្នាក់ទី ៧ ដល់ ១២ និងបានជំរុញឱ្យសាលារៀនផ្តល់លទ្ធភាពឱ្យសិស្សបានខ្ចីសៀវភៅសិក្សាគោល ដើម្បីស្វ័យសិក្សាបន្ថែមរៀងៗខ្លួន
- **៤. ការអប់រំក្រៅប្រព័ន្ធ ៖** កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាម អ៊ីនធឺណិត (BEEP) ដែលជួយឱ្យយុវជនកម្ពុជាបញ្ចប់ការអប់រំមូលដ្ឋាន តាមរយៈការរៀនដោយខ្លួនឯង តាមប្រព័ន្ធពីរបញ្ចូលគ្នា ដែលមានភាពបត់បែន និងទន់ភ្លន់។

# ៣.ការអនុវត្តការអប់រំឌីជីថលនៅកម្ពុជា

- **៥. ការអប់រំពិសេស ៖** ការបង្រៀនកម្មវិធីអប់រំពហុភាសាតាមស្ថានីយ វិទ្យុផ្សាយសំឡេងរបស់ខេត្តរតនគីរី និងមណ្ឌលគីរី សម្រាប់កម្រិតមត្តេយ្យសិក្សា និងបឋម សិក្សាថ្នាក់ទី ១ ដល់ទី៣ ជាភាសាទំពួន និងគ្រឹងក្នុងខេត្តរតនគីរី និងជាភាសាព្នងក្នុងខេត្ត មណ្ឌលគីរី។
- **៦. ការអប់រំបច្ចេកទេស ៖** មេរៀនសង្ខេបចែកជូនសិស្ស ថតវីដេអូបង្រៀន រៀបចំការបង្រៀនតាមប្រព័ន្ធអេឡិចត្រូនិក។ គ្រូជំនាញបានរៀបចំក្រុមសិស្សតាមជំនាញ និងតាមកម្រិតសិក្សា ដោយបានបង្កើតជាបណ្តាញសម្រាប់ទំនាក់ទំនងជាមួយសិស្ស និងក្លឹបសិក្សាតាមជំនាញ។
- **៧. គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ៖** នៅវិទ្យាស្ថានជាតិអប់រំ និងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ បានបង្កើតជាតបណ្តាញទំនាក់ទំនងរវាងគរុសិស្ស គរុនិស្សិតជាមួយនឹងគ្រូឧទ្ទេស។ គ្រូឧទ្ទេសអាចទម្លាក់ឯកសារមេរៀន ឬតំណរភ្ជាប់ឯកសារផ្សេងៗទៅឱ្យគរុសិស្ស គរុនិស្សិត ដើម្បីអាចសិក្សាតាមពេលម៉ោងក្នុងកាលវិភាគប្រចាំថ្ងៃដែលបានរៀបចំ។ គរុសិស្ស គរុនិស្សិត និងគ្រូឧទ្ទេសអាចពិភាក្សា ឆ្លងឆ្លើយគ្នាអំពីខ្លឹមសារមេរៀន ឬអំពីកិច្ចការគ្រូឧទ្ទេសដាក់ឱ្យធ្វើ។

# ៣.ការអនុវត្តការអប់រំឌីជីថលនៅកម្ពុជា

- IV. **កិច្ចសហការជាមួយដៃគូ និងផ្នែកឯកជន**
- ក្រសួងបានសហការជាមួយដៃគូឯកជន ដើម្បីធ្វើឱ្យកម្មវិធីអប់រំអេឡិចត្រូនិកកាន់តែមានភាពសម្បូរបែប៖
- ក្រុមហ៊ុន A.Z.E Innovation Tech Co., LTD បានព្រមព្រៀងផ្តល់សេវាប្រព័ន្ធសិក្សា E-School Cambodia ដោយឥតគិតថ្លៃសម្រាប់រយៈពេលពេញមួយឆ្នាំ ជូនដល់សិស្សទាំងអស់នៅកម្ពុជា
- ក្រុមអ្នកបច្ចេកវិទ្យា បានផលិតឯកសារមេរៀនជាវីដេអូ ល្បែងកំសាន្ត និងល្បងប្រាជ្ញា សម្រាប់ថ្នាក់ទី១ ដល់ថ្នាក់ទី៣ www.sangapac.com
- ក្រុមហ៊ុន Postcar បង្កើត App សម្រាប់ទូរស័ព្ទដៃ និងក្រុមហ៊ុន Wiki School បង្កើតវេទិកាឌីជីថល សម្រាប់ការចូលមើលវីដេអូបង្រៀន ដែលផលិតដោយក្រសួងអប់រំ យុវជន និងកីឡា
- ក្រៅពីនេះ ក្រុមហ៊ុន និងអ្នកជំនាញបច្ចេកវិទ្យាមួយចំនួនទៀតបានស្នើសុំកិច្ចសហការដោយផ្ទាល់ រួមមាន Khmer Academy, Edemy, PhumSchool, Test App, ICT Angkor, ReanTamChet, TesDopi, IKnowIKnow

# ៣.ការអនុវត្តការអប់រំឌីជីថលនៅកម្ពុជា

- V. **កិច្ចសហការ** ជាមួយធនាគារពិភពលោក និង មូលនិធិសកលសម្រាប់ការអប់រំ GPE ដើម្បីបង្កើតប្រព័ន្ធអប់រំអេឡិចត្រូនិករយៈពេលមធ្យមនិងវែង ក្រសួងកំពុងរកហិរញ្ញប្បទានបន្ថែម៖
- ធនាគារពិភពលោកប្រចាំកម្ពុជាកំពុងសិក្សា ដើម្បីបង្វែរកម្ចីចំនួន ៥ លានដុល្លារពីគម្រោងកែលម្អការអប់រំឧត្តមសិក្សា ដើម្បីគាំទ្រដល់ការអប់រំតាមប្រព័ន្ធអេឡិចត្រូនិក
- ក្រសួងអប់រំ យុវជន និងកីឡាកំពុងរៀបចំឯកសារនិងសំណើ ដើម្បីសុំជំនួយឥតសំណង ១០ លានដុល្លារពីមូលនិធិសកលសម្រាប់ការអប់រំ (GPE) ដើម្បីគាំទ្រនិងឆ្លើយតបទៅនឹងការជំងឺកូវីដ១៩ ជាពិសេសការជួយដល់សាលារៀននិងសិស្សនៅតំបន់ជនបទ និងអនុវត្តកម្មវិធីបើកចូលរៀនឡើងវិញក្រោយជំងឺកូវីដ១៩បានធូរស្រាល។ អាទិភាពមួយចំនួនត្រូវបានកំណត់ដូចខាងក្រោម៖
- ១) បន្តផលិតមាតិកាឌីជីថល និងវីដេអូបង្រៀន ដើម្បីផ្សព្វផ្សាយតាមរយៈប៉ុស្តិ៍ទូរទស្សន៍អប់រំ វិទ្យុ និងប្រព័ន្ធអនឡាញ ព្រមទាំងសម្រាប់កុមារមានពិការភាពផងដែរ

# ៣.ការអនុវត្តការអប់រំឌីជីថលនៅកម្ពុជា

- ២) បន្តផលិតមាតិកាឌីជីថល និងវីដេអូបង្រៀន ដើម្បីផ្សព្វផ្សាយតាមរយៈប៉ុស្តិ៍ទូរទស្សន៍អប់រំ វិទ្យុ និងប្រព័ន្ធអនឡាញ ព្រមទាំងសម្រាប់កុមារមានពិការភាព
- ៣) ផ្តល់នូវកញ្ចប់ទូរទស្សន៍និងបរិក្ខារដល់សាលារៀននៅជនបទ ដើម្បីបង្កើតបន្ទប់មួយសម្រាប់ការសិក្សា ពីចម្ងាយនិងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក
- ៤) បំពាក់បណ្ណាល័យមានស្តង់ដានិងសៀវភៅសិក្សាដល់សាលារៀននៅជនបទ និងសាលាគរុកោសល្យ
- ៥) លើកកម្ពស់សុខភាពសិក្សា និងអនាម័យ
- ៦) អភិវឌ្ឍវិធីសាស្ត្របង្រៀន និងការគ្រប់គ្រងតាមសាលារៀន នៅតាមសាលាគរុកោសល្យ
- ៧) អភិវឌ្ឍសមត្ថភាពសាលារៀននៅជនបទនិងនាយកសាលា អំពីការសិក្សាពីចម្ងាយ
- ៨) គាំទ្រដល់ការបំប៉នសិស្ស ដើម្បីឱ្យពួកគេអាចរៀនទាន់កម្មវិធីសិក្សា
- ៩) ផ្តល់ការគាំទ្របន្ថែមដល់សាលារៀនមួយចំនួននៅជនបទ និងសិស្សមានពិការភាព។

# ៣.ការអនុវត្តការអប់រំឌីជីថលនៅកម្ពុជា

- គ្រឹះស្ថានសិក្សាមួយចំនួន ទាំងរដ្ឋ និងឯកជន បានប្រើប្រាស់នូវកម្មវិធីសិក្សាដែលមានដូចខាងក្រោម ៖
- ការអប់រំតាមប្រព័ន្ធអេឡិចត្រូនិក (E-Learning) ជាប្រព័ន្ធនៃការអប់រំតាមបែបឌីជីថលដែលមានមូលដ្ឋានចេញពីការអប់រំផ្លូវការ ប្រើប្រាស់ធនធានអេឡិចត្រូនិកជាជំនួយ។
- ការអប់រំពីចម្ងាយ (Distance Learning) ជាវិធីសាស្រ្តមួយ ដែលសិស្សអាចទទួលបានការអប់រំ សម្រាប់ការអភិវឌ្ឍសម្បទាទាំង៤ (ពុទ្ធិសម្បទា បំណិនសម្បទា កាយសម្បទា និងចរិយាសម្បទា) ដោយពុំចាំបាច់មានវត្តមាន ឬជួបគ្រូដោយផ្ទាល់។
- គ្រឹះស្ថានសិក្សាមួយចំនួនក៏បានផ្សារភ្ជាប់កម្មវិធី ការអប់រំពីចម្ងាយ ជាមួយ ប្រព័ន្ធនៃការសិក្សាតាមបែបចម្រុះ (Blended Learning) ឬ ដែលផ្សារភ្ជាប់ជាមួយប្រព័ន្ធគ្រប់គ្រងការសិក្សា (Learning Management System)។

# ៣.ការអនុវត្តការអប់រំឌីជីថលនៅកម្ពុជា

- ក្រសួងនឹងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការអប់រំឌីជីថល និងការអប់រំពីចម្ងាយដោយមានសមាសភាគ ចំនួន៤ រួមមាន៖
- ១. ហេដ្ឋារចនាសម្ព័ន្ធសម្រាប់គ្រប់គ្រងទិន្នន័យនៃការអប់រំឌីជីថល ដោយផ្តោយលើការរៀបចំបង្កើតមជ្ឈមណ្ឌលទិន្នន័យ (Data Center)
- ២. សកម្មភាពផលិតវីដេអូនៃការបង្រៀន ដោយរួមបញ្ចូលនូវការបញ្ជ្រាបវិធីសាស្ត្របង្រៀនបែបថ្មី និងការឆ្លើយតបចំពោះការអប់រំពិសេស
- ៣. ហេដ្ឋារចនាសម្ព័ន្ធនៃការផលិតវីដេអូនៃការបង្រៀន ដោយផ្តោតលើការបង្កើតស្ទូឌីយ៉ូសម្រាប់ផលិតវីដេអូ និងមាតិកាឌីជីថលដទៃ និងស្ទូឌីយ៉ូខ្នាតធំសម្រាប់វេទិកាអប់រំ
- ៤. វេទិកាឌីជីថលសម្រាប់ការអប់រំតាមប្រព័ន្ធអេឡិចត្រូនិក ដោយផ្តោតលើការរៀបចំបង្កើត App និង Website សម្រាប់ការផ្តល់សេវាអប់រំតាមប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធគ្រប់គ្រងការសិក្សា ដោយផ្អែកលើបរិបទនៃការអប់រំនៅកម្ពុជា។




# ទី៤
# បំណិនសតវត្សទី២១ និង កំណែទម្រង់វិស័យអប់រំ ដើម្បីបរិវត្តកម្មឌីជីថល

# ៤. ការបណ្ដុះបំណិនសតវត្សទី២១

- **តើយុវជនត្រូវការអ្វីខ្លះក្នុងយុគសម័យបដិវត្តន៍ឧស្សាហកម្មទី៤?**
- បរិវត្តកម្មឌីជីថលនេះទាមទារនូវការបណ្ដុះបណ្ដាលជំនាញថ្មី ដើម្បីឆ្លើយតបទៅនឹងនិន្នាការវិវត្តន៍យ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា។ តាមការព្យាករណ៍របស់វេទិកាសេដ្ឋកិច្ចពិភពលោក (WEF), នៅក្នុងរយៈពេល ១០ ខាងមុខបំណិនចំនួន ៣៥% ដែលចាំបាច់សម្រាប់ទីផ្សារការងារនឹងប្រែប្រួលខុសពីសព្វថ្ងៃ។ បរិវត្តកម្មឌីជីថលនេះនឹងធ្វើឱ្យមានការផ្លាស់ប្ដូរនៃតម្រូវការជំនាញ ដោយសារតែស្វ័យប្រវត្តិនីយកម្ម។
- ដោយសារតែការផ្លាស់ប្ដូរយ៉ាងឆាប់រហ័សនេះ គេមិនអាចព្យាករណ៍បានថា សិស្សដែលកំពុងសិក្សានៅក្នុងសាលារៀននាពេលបច្ចុប្បន្នត្រូវមាន «បំណិនបច្ចេកទេស» អ្វីខ្លះដើម្បីតម្រូវតាមទីផ្សារពលកម្មនាពេលអនាគត។ ការអង្កេតតាមក្រុមហ៊ុនចំនួន៩០០ បានបញ្ជាក់ថា «បំណិនទន់» ឬ«បំណិនសតវត្សទី២១» គឺជាបំណិនដែលសមស្របបំផុតសម្រាប់អនាគត។ យុវជនត្រូវមានការទទួលខុសត្រូវ អាកប្បកិរិយាវិជ្ជមាន ដើម្បីរៀនជាប់ជានិច្ច ក្នុងគោលដៅចាប់យកជំនាញថ្មីនិងបន្សាំទៅនឹងស្ថានភាពតែងតែប្រែប្រួលជានិច្ច។

# ៤. ការបណ្ដុះបំណិនសតវត្សទី២១

- **បំណិនសតវត្សរ៍ទី២១** សំដៅលើបំណិនទន់ និងបំណិនបុរេវិជ្ជាជីវៈដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុងទីផ្សារការងារដែលយុវជនកម្ពុជាត្រូវមាន។ បំណិនសតវត្សទី២១ គឺជាជំនាញដែលជួយពង្រឹង និងអភិវឌ្ឍសមត្ថភាពសិស្សានុសិស្ស ដើម្បីទទួលបានជោគជ័យក្នុងអាជីពការងារនាសម័យបច្ចេកវិទ្យាទំនើបនេះ។ បំណិនសតវត្សទី២១ ត្រូវបានបែកជាសមាសភាគ ៣ គឺ៖
- **ទី១-បំណិនសិក្សារៀនសូត្រ៖** (១) ការត្រិះរិះពិចារណា (២) ការគិតដោយមានភាពច្នៃប្រឌិត និងនវានុវត្តន៍ (៣) ការសហការ និង (៤) ការប្រាស្រ័យទាក់ទង។
- **ទី២-បំណិនអក្ខរកម្ម៖** សិស្សត្រូវមាន៖ (១) អក្ខរកម្មព័ត៌មានវិទ្យា (២) អក្ខរកម្មផ្នែកប្រព័ន្ធផ្សព្វផ្សាយ និង (៣) អក្ខរកម្មផ្នែកបច្ចេកវិទ្យា ។ និង
- **ទី៣-បំណិនជីវិត៖** (១) ភាពទន់ភ្លន់និងសម្របសម្រួល (២) ការចេះផ្តួចផ្តើមគំនិត (៣) ភាពជាអ្នកដឹកនាំ (៤) ផលិតភាពការងារ និង (៥) បំណិនសង្គម។

# លក្ខណៈសម្បត្តិនៃសិស្សសាលារៀនជំនាន់ថ្មី

ការផ្តើមគំនិត និង សហគ្រិនភាព

ភាពរហ័សរហួន និង ការទទួលអនុវត្តតាម

មានអានុភាពឈានមុខ ចំពោះទំនាក់ទំនង និងការសហការ

ការគិតបែបវិភាគ ស៊ីជម្រៅ និងការដោះស្រាយបញ្ហា

**លទ្ធផល អ្នករៀនសូត្រ នៅ សតវត្សទី ២១**

ការទំនាក់ទំនងដោយ និយាយ និងសរសេរ យ៉ាងសក្តិសិទ្ធ

វិភាគវាយតម្លៃ ព័ត៌មាន

ចង់ឃើញ ចង់ដឹង និង ការស្រមើលស្រមៃ

# បំណិននិងសមត្ថភាពសតវត្សទី ២១

- **របៀបគត**

1. ឆ្លៃប្រឌិតនិងនវានុវត្តន៍

2. ត្រិះរិះពិចារណា ដោះស្រាយបញ្ហា និងសម្រេចចិត្ត

3. រៀនដើម្បីចេះរៀន Metacognition

- **របៀបធ្វើការ**

4. ទំនាក់ទំនង

5. សហការ (ធ្វើការជាក្រុម)

- **ឧបករណ៍ធ្វើការ**

6. អក្ខរកម្មឌីជីថល

7. ICT

- **របៀបរស់នៅ**

8. ពលរដ្ឋល្អ – ជាតិ និងសាកល

9. ជីវិត និងការងារ– បំណិនគ្រប់គ្រងជីវិត និងការងារ

10. ការទទួលខុសត្រូវផ្ទាល់ខ្លួន និងក្នុងសង្គម –រួមទាំងមានកម្រិតវប្បធម៌ និងសមត្ថភាពខ្ពស់

# ជំនាញគន្លឹះសម្រាប់សតវត្សទី២១



1. **បំណិនគ្រិះរិះ និងដោះស្រាយបញ្ហា** (Critical thinking and problem solving)
2. **បំណិនច្នៃប្រឌិត និងនវានុវត្តន៍** (Creativity and innovation)
3. **ការយល់ពីវប្បធម៌ប្រទេសផ្សេងៗ** (Cross-cultural understanding)
4. **បំណិនសហការ ធ្វើការជាក្រុម** និងភាពជាអ្នកដឹកនាំ (Collaboration, teamwork & leadership)
5. **បំណិនគមនាគមន៍ព័ត៌មាន** និងអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ (Communications, information & media literacy)
6. **អក្ខរកម្មកុំព្យូទ័រ និងបច្ចេកវិទ្យាព័ត៌មាន** (Computing & ICT literacy)
7. **បំណិនអាជីព** និង**រៀន** (Career & learning skills)
8. **បំណិនខាងផ្នែកផ្លាស់ប្តូរ** (Change)

# ៤. ការបណ្តុះបំណិនសតវត្សទី២១

- **ការចេះបង្កើតថ្មី និងនវានុវត្តន៍** គឺជាបំណិនដែលជួយឱ្យសិស្សអាចប្រកួតប្រជែងបាននៅក្នុងសតវត្សទី២១បាន។ សិស្សត្រូវមានបំណិនសតវត្សទី២១ ដូចជាបំណិនត្រិះរិះពិចារណា សហការ បង្កើតថ្មី ប្រាស្រ័យទាក់ទង និងដោះស្រាយបញ្ហាសង្គម សេដ្ឋកិច្ច បច្ចេកវិទ្យា និងនយោបាយ។
- **យុវជនសតវត្សរ៍ទី២១** ត្រូវមានបំណិនទន់ និងបំណិនបុរេវិជ្ជាជីវៈឱ្យបានច្បាស់លាស់។ បំណិនទន់ និងបំណិនបុរេវិជ្ជាជីវៈសំដៅលើបំណិនដែលទាក់ទងនឹងបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនមាន របៀបកសាងទំនាក់ទំនង ការធ្វើសហប្រតិបត្តិការ ការងារជាក្រុម និងការបង្កើតថ្មីជាដើម។ ទន្ទឹមគ្នានេះផ្នែកមួយនៃបំណិនមូលដ្ឋាននិងបំណិនអាជីព ស្ថិតក្នុងទម្រង់បំណិនអាជីវកម្ម ផ្តោតលើការគ្រប់គ្រងផែនការអាជីវកម្ម ការសម្រេចចិត្ត ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាមួយអតិថិជន។
- យើងអាចបណ្តុះបណ្តាលមនុស្សសតវត្សទី២១បានទេ ប្រសិនបើសាលាយើងភាគច្រើនលើសលុបនៅតែជាសាលាសតវត្សទី២០? តើត្រូវចាប់ផ្តើមពីអ្វី?




# ទី៥៖ កំណែទម្រង់សាលារៀន

# កំណែទម្រង់ពីថ្នាក់កណ្ដាលទៅសាលារៀន

- **ការរៀបចំផែនការអប់រំ៖** ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) កំណត់គោលដៅនៃប្រព័ន្ធអប់រំ និងសូចនាករតាមអនុវិស័យ
- **កំណែទម្រង់សសរស្តម្ភទាំង៥៖** ១) គ្រូបង្រៀន ២) វង្វាយតម្លៃសិក្សា ៣) កម្មវិធីសិក្សា និងសៀវភៅគោល ៤) អធិការកិច្ច និង ៥) ឧត្តមសិក្សា
- **ការគ្រប់គ្រងសាលារៀន៖** ការអនុវត្តកំណែទម្រង់កម្រិតសាលារៀនទទួលបានលទ្ធផលល្អប្រសើរ ដោយបង្កើតបានជាសាលាគំរូ ៣កម្រិត (**លទ្ធផលសិក្សាសិស្ស**)៖
- **ទី១- សាលាជំនាន់ថ្មី** NGS
- **ទី២- សាលាគ្រប់គ្រងមានប្រសិទ្ធភាព** SBM (**គម្រោង** SEIP)
- **ទី៣- ការលើកកម្ពស់គុណភាពអប់រំតាមសាលាធនធាន និងសាលាផ្សេងទៀត ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយឧស្សាហកម្ម**

# ៥.កំណែទម្រង់អប់រំ ដើម្បីលើកកម្ពស់បរិវត្តកម្មឌីជីថល នៃការអប់រំ និងបំណិនសតវត្សទី២១

- ដើម្បីអនុវត្តការអប់រំបែបឌីជីថលឱ្យបានកាន់តែប្រសើរ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំកម្មវិធីកំណែទម្រង់វិស័យអប់រំ ដើម្បីដាក់ទុនវិនិយោគលើហេដ្ឋារចនាម្ព័ន្ធរូបវន្ត និងហេដ្ឋារចនាសម្ព័ន្ធផ្នែកទន់ ជាពិសេសការពង្រឹងការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព (SBM) ការបង្កើតសាលាជំនាន់ថ្មី (NGS) ការធ្វើកំណែទម្រង់វិធីសាស្ត្របង្រៀន ការកែលម្អបរិស្ថានសិក្សា និងការលើកកម្ពស់ការសិក្សាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) ជាដើម។
- ដើម្បីឆ្លើយតបជាមួយនឹងតម្រូវការធនធានមនុស្សផ្នែកឌីជីថល ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតឱ្យមានសាលាជំនាន់ថ្មីដែលបញ្ចូលនូវកម្មវិធីសិក្សាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) និងការបណ្ដុះបណ្ដាលការសរសេរកូដ រួមទាំងកម្មវិធីសិក្សាដែលជាជំនាញទន់ជាច្រើនទៀតដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្ដែងក្នុងសតវត្សទី ២១។

# ៥.កំណែទម្រង់ការអប់រំ ដើម្បីលើកកម្ពស់បរិវត្តកម្មឌីជីថល នៃការអប់រំ និងបំណិនសតវត្សទី២១

- ក្រសួងបានរៀបចំការអប់រំ ឱ្យឆ្លើយតបជាមួយយុគ្គសម័យបច្ចេកវិទ្យា តាមរយៈការធ្វើកំណែទម្រង់សាលារៀន និងកំណែទម្រង់ការបណ្តុះបណ្តាលគ្រូ ដោយធ្វើយ៉ាងណាឱ្យភាគីពាក់ព័ន្ធទាំងអស់មានសមត្ថភាពខ្ពស់ផ្នែកបច្ចេកវិទ្យា មុននឹងចែករំលែកបន្តទៅដល់សិស្សានុសិស្សដែលជាធនធានមនុស្សជំនាន់ថ្មី ដើម្បីចូលរួមក្នុងការប្រកួតប្រជែងក្នុងទីផ្សារការងារ។ សិស្សានុសិស្ស ឬនិស្សិត ដែលជាយុវជនជំនាន់ក្រោយមានឱកាសកាន់តែច្រើន ក្នុងការសិក្សាឱ្យបានទូលំទូលាយពីបច្ចេកវិទ្យា។ លក្ខខណ្ឌនេះជាឱកាសក្នុងការទាញយកចំណេះដឹងដែលមានជុំវិញ ពិភពលោកដើម្បីអភិវឌ្ឍសមត្ថភាពខ្លួនឯង។ ហេតុនេះសិស្សនិស្សិតគួរចេះស្វែងរកប្រភពចំណេះដឹងជាមូលដ្ឋាន សម្រាប់បន្តអភិវឌ្ឍសមត្ថភាពក្នុងយុគសម័យឌីជីថល។
- ក្រសួងបានបង្កើតសាលារៀនចជំនាន់ថ្មីចំនួន ១១ កន្លែង ដើម្បីសាកល្បងកំណែទម្រង់ការអប់រំជាប្រព័ន្

# សាលារៀនជំនាន់ថ្មី (NGS)



$6,000 in income each year

- Our school is nearly 50% there









The Demonstration School and two other schools

**Additional Ideas for Sustainability**

- **Social Equity Fund:**
- **Innovation Grants**

# កម្មវិធីសិក្សា STEM នៅសាលារៀនជំនាន់ថ្មី




- ផ្តល់សេរីភាពដល់សិស្ស ក្នុងការជ្រើសរើស មុខវិជ្ជា STEM ណាមួយ ដែលជាឧបនិស្ស័យរបស់ខ្លួន។

- ថ្នាក់មូលដ្ឋានដែលបានរៀបចំសម្រាប់សិស្សជ្រើសរើស មាន ៤ ប្រភេទគឺ៖

1. ថ្នាក់រូបវិទ្យា
2. ថ្នាក់គីមីវិទ្យា
3. ថ្នាក់ជីវវិទ្យា
4. ថ្នាក់បច្ចេកវិទ្យាព័ត៌មាន(ICT)

# Robotic Club: សម្រាប់អ្នកចូលចិត្តបច្ចេកវិទ្យា









# THE E2STEM CURRICULUM

*What we do in order to realise our Purpose and achieve our Mission*



# ៥.កំណែទម្រង់អប់រំ ដើម្បីលើកកម្ពស់បរិវត្តកម្មឌីជីថល នៃការអប់រំ និងបំណិនសតវត្សទី២១

- គុណភាពអប់រំមានភាពល្អប្រសើរជាងមុន ហើយសិស្សានុសិស្សត្រូវបានបំពាក់ដោយជំនាញរឹងនិងជំនាញទន់ ជាពិសេស គំនិតផ្តួចផ្តើមថ្មី ការគិតត្រិះរិះ និងការដោះស្រាយបញ្ហា។
- ក្រសួងបានជ្រើសរើសសាលារៀនចំនួន ១០០ បន្ថែមទៀត ដើម្បីបង្កើតសាលារៀនគំរូកម្រិតទី២ ដែលយើងអនុវត្តក្នុងគម្រោង «ការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព (SEIP)»។
- ក្រសួងក៏បានដាក់ចេញគោលដៅប្រែក្លាយសាលាធនធាន ចំនួន ៥០ ឱ្យក្លាយជាសាលាគំរូ។ គោលដៅរបស់យើង គឺការបង្កើត «សាលារៀនឆ្លាតវៃ» សម្រាប់យុគសម័យឌីជីថល។

# ៥.កំណែទម្រង់ការអប់រំ ដើម្បីលើកកម្ពស់បរិវត្តកម្មឌីជីថល នៃការអប់រំ និងបំណិនសតវត្សទី២១

- ការលើកកម្ពស់ការអប់រំឌីជីថល ទាមទារនូវបរិវត្តកម្មនៃប្រព័ន្ធអេកូឡូស៊ីនៃការអប់រំឌីជីថល ដូចជាការបង្កើតទំនាក់ទំនងរវាងការអប់រំឌីជីថលនៅក្នុងសាលារៀន (សិស្ស គ្រូ សកម្មភាពថ្នាក់ រៀន និងកម្មវិធីសិក្សា)ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសាសារៀនដោយប្រើប្រាស់បច្ចេកវិទ្យាការរៀបចំការប្រកួតមនុស្សយន្ត ការតស៊ូមតិ ពិព័ណ៌វិទ្យាសាស្រ្ត និងបច្ចេកវិទ្យា ការតម្រង់ទិសវិជ្ជាជីវៈការផ្សារភ្ជាប់ទៅនឹងអនុវិស័យឧត្តមសិក្សា និងការហាត់ការនៅក្នុងក្រុមហ៊ុនឯកជន។
- តាមបទពិសោធគម្រោងដែលអនុវត្តកន្លងមក ការអប់រំបែបឌីជីថលទាមទារនូវបុគ្គលិកលក្ខណៈខ្លាំង ដូចជាការចេះធ្វើការជាក្រុម ចំណេះដឹងខាងផ្នែកឧបករណ៍ឌីជីថល។
- «ការអប់រំបែបឌីជីថល» មានគោលដៅ ប្រើប្រាស់បច្ចេកវិទ្យា ដើម្បីដោះស្រាយបញ្ហាសេដ្ឋកិច្ច និងសង្គមក្នុងបរិបទនៃបដិវត្តឧស្សាហកម្មទី៤ និងការបង្កើតទីក្រុងឆ្លាត (Smart city) និងអគារឆ្លាតផងដែរ

# ៥.គុណសម្បត្តគ្រូក្នុងយុគសម័យឌីជីថល



# ៥.តួនាទីគ្រូក្នុងយុគសម័យឌីជីថល

- គ្រូបង្រៀនដើរតួនាទីយ៉ាងសំខាន់ ក្នុងការបរិវត្តកម្មឌីជីថលក្នុងវិស័យអប់រំ។ គ្រូត្រូវប្រើបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ និងធនធានក្នុងបណ្ណាល័យ ដើម្បីធ្វើឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព។
- គ្រូត្រូវអភិវឌ្ឍចំណេះដឹងបច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និងបំណិន សម្រាប់អនុវត្តក្នុងការបង្រៀននិងរៀន និងមានឆន្ទៈស្វ័យសិក្សាស្រាវជ្រាវបំពេញបន្ថែមទាំងចំណេះដឹងមូលដ្ឋាន ទាំងបច្ចេកទេសបង្រៀនថ្មីៗតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ។
- កំណែទម្រង់វិស័យអប់រំផ្តោតជាសំខាន់លើការបង្កើតចំណេះដឹង បំណិន និងសមត្ថភាពរបស់គ្រូបង្រៀន។ គ្រូបង្រៀន គឺជាអ្នកអនុវត្តកំណែទម្រង់នៅក្នុងថ្នាក់រៀន និងជា «អ្នកដឹកនាំក្នុងថ្នាក់រៀន»។

# ៥.គុណសម្បត្តិគ្រូក្នុងយុគសម័យឌីជីថល

- ទីមួយ-ចំណេះដឹងខ្លឹមសារមេរៀនរឹងមាំ និងមានវប្បធម៌ទូទៅទូលំទូលាយ (រួមទាំងចំណេះដឹងផ្នែកភាសាបរទេសផងដែរ)
- ទីពីរ- បំណិនវិជ្ជាជីវៈ ជាពិសេសចំណេះដឹងខាងផ្នែកចិត្តវិទ្យា និងគរុកោសល្យ រួមទាំងមានសមត្ថភាពក្នុងការស្រាវជ្រាវ
- ទីបី- ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីមានបទពិសោធវិជ្ជាជីវៈកាន់តែខ្លាំងក្លាឡើង
- ទីបួន-សីលធម៌វិជ្ជាជីវៈ ដើម្បីបង្កើតវប្បធម៌សាលារៀនវិជ្ជមាន និងផ្តល់ឱកាសឱ្យសិស្សបានសិក្សារៀនសូត្រ ដើម្បីសម្រេចបានសក្តានុពល
- ទីប្រាំ-បំណិនឌីជីថល និងការប្រើប្រាស់បច្ចេកវិទ្យា ក្នុងការអនុវត្តវិធីសាស្រ្តបង្រៀន ដើម្បីអប់រំសិស្ស ឱ្យមានបំណិនសតវត្សទី២១។ សរុបមក ដើម្បីបណ្តុះបណ្តាលធនធានមនុស្សសម្រាប់សតវត្សទី២១ គេត្រូវ បណ្តុះបណ្តាលគ្រូដែលមានចំណេះដឹង បំណិន និងសមត្ថភាពសតវត្សទី២១។

# ការគ្រប់គ្រងសាលារៀនមានប្រសិទ្ធភាព (SBM)

- ទី ១- វាយតម្លៃ Assessment ៖ ការធ្វើតេស្តដោយតម្លាភាព
- ទី ២- គណនេយ្យភាព Accountability ៖ សាលារៀនមានបញ្ហាអ្វី?
- ទី ៣- ស្វ័យភាព Autonomy៖ គណៈកម្មការគ្រប់គ្រងសាលារៀន
- ទី ៤- ការចូលរួម PArticipation៖ ការចូលរួមរបស់មាតាបិតា និង ភាគពាក់ព័ន្ធ

- ផ្លាស់ប្តូរវប្បធម៌សាលារៀន
- លទ្ធផលសិក្សាសិស្សកែលម្អ
- TUP, LUP

# គណនេយ្យភាព និងស្វ័យភាព



# ទី៦

# ការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព



# ៦. ការគ្រប់គ្រងផ្ដោតលើលទ្ធផល

- ការឆ្លើយតប៖
- ១) យុទ្ធសាស្ត្រចក្កោណ
- ២) សេដ្ឋកិច្ចឌីជីថល
- ៣) ការអប់រំឌីជីថល
- យុទ្ធសាស្ត្រ៖
- ពីការគ្រប់គ្រងដោយផ្ដោតលើធាតុចូល (INPUTS) ឆ្ពោះទៅកាន់
- ការគ្រប់គ្រងផ្ដោតលើលទ្ធផល (RESULT-BASED MANAGEMENT)៖
- លទ្ធផលសិក្សារបស់សិស្ស និងធនធានមនុស្សមានគុណភាព
- ជាពលរដ្ឋល្អ

# ៦. គំរោងទម្រង់ការគ្រប់គ្រងធនធានមនុស្ស

- **១- ការពង្រឹងសមត្ថភាព៖**
- ការបណ្តុះបណ្តាលគ្រូ (PRESET)
- ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD)
- **២- ការលើកទឹកចិត្ត៖**
- ការវាយតម្លៃការងារប្រចាំឆ្នាំ
- ការដំឡើងបៀវត្ស និងឋានន្តរស័ក្តិ
- **៣- ការផ្តល់ឱកាស៖**
- ការអនុវត្តគន្លងអាជីព៖ (1) អ្នកមានវិជ្ជាជីវៈដំបូង (2) អ្នកឯកទេស (3) អ្នកឯកទេសជាន់ខ្ពស់
- ការចូលរួម

# ៦. ការកសាងប្រព័ន្ធ និងការពង្រឹងសមត្ថភាព

- **ការផ្លាស់ប្តូរផ្នត់គំនិត និងរបៀបធ្វើការ៖**
- **ពីឯធីសាស្រ្តគម្រោង** (USEDSP-II & II; SIEP, GPE, TEC etc.)
- **ទៅការគ្រប់គ្រងជាប្រព័ន្ធ៖** រៀបចំតារាងគ្រប់គ្រងផ្តោតលើលទ្ធផល ដោយមានធាតុចូល សម្រាប់អនុវត្តគោលនយោបាយតាមអនុវិស័យ ដើម្បីសម្រេចគោលដៅ ដែលដាក់ចេញ
- **ការបង្កើតគន្លងអាជីព៖** ដោយអនុវត្តនៅតាមគ្រឹះស្ថានសិក្សាមានប្រសិទ្ធភាព
- **ការអភិវឌ្ឍសមត្ថភាពអនុវត្តកំណែទម្រង់៖** នៅដំណាក់កាលទី១ ទទួលស្គាល់អ្នកដែលជួយគាំទ្រដល់ការអនុវត្តកំណែទម្រង់កម្រិតសាលារៀន
- **ការអភិវឌ្ឍសមត្ថភាពអ្នកឯកទេសថ្នាក់កណ្តាល៖** អ្នកតែងសៀវភៅ អ្នកឯកទេសកម្មវិធីសិក្សា (វិធីសាស្រ្តបង្រៀន) វង្វាយតម្លៃ (ជួយសាលា PISA)

# ៦. កំណែទម្រង់សាលាគរុកោសល្យ

- **ទី ១- កម្មវិធីបណ្ដុះបណ្ដាល និងវិក្រឹតការ៖** «ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន»
- **ទី ២-សមត្ថភាពវិជ្ជាជីវៈគ្រូឧត្ដម៖** (១) ខ្លឹមសារមេរៀន (២) គរុកោសល្យ ជាពិសេសវិធីសាស្ត្របង្រៀនសម្បូរបែប តាមបែបសកម្ម (៣) បច្ចេកវិទ្យា
- **ទី៣-អគារហេដ្ឋារចនាសម្ព័ន្ធ៖** បណ្ណាល័យ និងសម្ភារឧបទេស
- **ទី៤-ភាពជាអ្នកដឹកនាំគ្រប់គ្រង៖** ដឹកនាំការអនុវត្ត
- **ទី៥-ការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តកម្មវិធីសិក្សាគរុកោសល្យ៖**
**ទី៦-ការធានាគុណភាព៖** ប្រព័ន្ធធានាគុណភាពផ្ទៃក្នុង គណៈកម្មាធិការជាតិទទួលស្គាល់គុណភាពអប់រំ ការវាយតម្លៃឯករាជ្យ



# វប្បធម៌រលត់ ជាតិរលាយ

# វប្បធម៌ពណ្ណរាយ ជាតិថ្កើងថ្កាន